

# កម្មវិធីភាពធន់ និងសុវត្ថិភាពផ្លូវរថភ្លើងរបស់ MBTA

## សេចក្តីប្រកាសជូនដំណឹង៖ ការបង្វែរខ្សែឡានក្រុង នៅ Newburyport/Rockport

MBTA កំពុងដំឡើងប្រព័ន្ធស្លាកសញ្ញាថ្មី ហៅថា ការត្រួតពិនិត្យរថភ្លើងដោយស្វ័យប្រវត្តិ (ATC) ជាផ្នែកមួយនៃ ការត្រួតពិនិត្យរថភ្លើងវិជ្ជមាន (PTC) ដែលជាប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពដែលដាក់ឲ្យអនុវត្តក្នុងសហព័ន្ធ ដែលពិនិត្យទីតាំង ទិសដៅ និងល្បឿនរបស់រថភ្លើងតាមម៉ោងជាក់ស្តែង ហើយកាត់បន្ថយល្បឿន នៅពេលមានការចាំបាច់ដើម្បីជួយបង្ការការបុកគ្នា ។

ក្រុមការងាររបស់គម្រោងសូមជម្រាបជូនដំណឹងដល់សហគមន៍ទាំងមូលថា នឹងមានការផ្តាច់សេវារយៈពេល 9 ថ្ងៃ (ចាប់ពីថ្ងៃ ច័ន្ទ ទី 20 ខែមីនា ដល់ថ្ងៃ អង្គារ ទី 28 ខែមីនា) ពី Swampscott ទៅ North Station ដើម្បីអនុញ្ញាតឲ្យមានការងារកែលម្អស្លាកសញ្ញាជាបន្ត ។ ឡានក្រុងនឹងជំនួសឲ្យសេវាកម្មរថភ្លើងធម្មតានៅថ្ងៃចុងសប្តាហ៍ និងថ្ងៃធ្វើការ ។

រថភ្លើងដែលរត់ទៅមកពី Lynn និង Swampscott នឹងត្រូវផ្អាកក្នុងកំឡុងពេលបង្វែរផ្លូវនេះ ហើយឡានក្រុងរត់ទៅមកនឹងមាននៅ Lynn សម្រាប់សេវាកម្មដឹកជញ្ជូនចូលក្នុង និងចេញក្រៅ ។

អ្នកធ្វើដំណើរគួរកត់សម្គាល់ថា កង់មិនត្រូវបានអនុញ្ញាតឲ្យមាននៅលើឡានក្រុងឡើយ ហើយថ្លៃសំបុត្ររថភ្លើងធម្មតានឹងត្រូវយក រវាងស្ថានីយ៍ Swampscott និង Newburyport/Rockport ។

សូមអរគុណទុកជាមុន សម្រាប់កិច្ចសហការរបស់បងប្អូន ។ យើងសូមវាយតម្លៃខ្ពស់ចំពោះការអត់ធ្មត់របស់អ្នក នៅពេល **MBTA** ចាត់វិធានការដ៏សំខាន់នេះ ក្នុងការធ្វើឲ្យផ្លូវរថភ្លើងកាន់តែមានសុវត្ថិភាពសម្រាប់អតិថិជន ដោយការអនុវត្តកម្មវិធី **PTC** នេះ ។

ប្រសិនបើអ្នកមានសំណួរណាមួយ សូមទាក់ទងមកកម្មវិធី **PTC** តាមលេខ **617-721- 7506** ឬ PTCProgram@mbta.com ។